Disability Inclusion
Education for All

Khmer | **ភាសាខ្មែរ**

**សន្លឹកព័ត៌មានអំពីការរួមបញ្ចូលពិការភាព**

# ការរួមបញ្ចូលពិការភាព – សន្លឹកព័ត៌មានការពិតសម្រាប់គ្រួសារ

ការរួមបញ្ចូលពិការភាពគឺជាវិធីសាស្ត្រថ្មីមួយ ដើម្បីជួយយើងកែលម្អការគាំទ្រសម្រាប់សិស្សដែលមានពិការភាព និងសាងសង់សាលារៀនដែលមានការរួមបញ្ចូលកាន់តែច្រើនសម្រាប់សិស្សរបស់យើងទាំងអស់។

សាលារៀនដែលមានការរួមបញ្ចូលមានលទ្ធផលកាន់តែប្រសើរក្នុងការរៀនសូត្រ មានការចូលរួមពាក់ព័ន្ធ និងសុខុមាលភាពសម្រាប់សិស្សទាំងអស់។

ការរួមបញ្ចូលពិការភាពនឹងជួយដល់សាលារៀននានាឱ្យយល់ដឹងបានកាន់តែច្បាស់អំពីអ្វីដែលសិស្សរបស់យើងត្រូវការដើម្បីជួយពួកគេរៀនសូត្រ តាមរយៈ៖

- គំរូការផ្តល់មូលនិធិថ្មីដែលមានការវិនិយោគកាន់តែច្រើន
- ដំណើរការផ្អែកលើចំណុចខ្លាំងហៅថាកម្រងព័ត៌មានអំពីការរួមបញ្ចូលពិការភាពដើម្បីជួយកំណត់ពីសេចក្តីត្រូវការ និងការកែសម្រួលដែលត្រូវការចាំបាច់របស់សិស្ស
- ការបណ្តុះបណ្តាល និងការបង្វឹកកាន់តែច្រើនសម្រាប់គ្រូបង្រៀន និងបុគ្គលិកសាលាអំពីវិធីសាស្ត្រល្អបំផុតដើម្បីគាំទ្រដល់ការរៀនសូត្ររបស់សិស្ស។

***គំរូការផ្តល់មូលនិធិថ្មីដែលមានការវិនិយោគកាន់តែច្រើន***

គំរូការផ្តល់មូលនិធិថ្មីផ្តល់ការវិនិយោគបន្ថែមដែលសាលារៀនអាចប្រើប្រាស់ដើម្បីគាំទ្រដល់សិស្សជាច្រើន រួមមានសិស្សដែលមានជំងឺអូទីស្សឹម (autism) ការពិបាកក្នុងការរៀនសូត្រ និងច្រើនទៀត។

ការវិនិយោគបន្ថែមនេះនឹងផ្តល់ការគាំទ្រសម្រាប់សិស្សដែលមានពិការភាព រួមមានសិស្សដែលមិនមានសិទ្ធិទទួលមូលនិធិដោយផ្ទាល់តាមរយៈកម្មវិធីសម្រាប់សិស្សដែលមានពិការភាព (PSD) ក្នុងពេលកន្លងមក។

សាលារៀនទាំងឡាយអាចប្រើប្រាស់មូលនិធិនេះសម្រាប់សកម្មភាពនានាជាច្រើន រួមមាន៖

- ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍អាជីពជំនាញបន្ថែមទៀតសម្រាប់គ្រូបង្រៀន និងបុគ្គលិកសាលា
- ទទួលបានដំបូន្មានអ្នកជំនាញអំពីពិការភាព
- ជួលគ្រូបង្រៀន ឬបុគ្គលិកផ្សេងទៀតដើម្បីជួយរៀបចំផែនការ និងផ្តល់ការផ្លាស់ប្តូរនានាសម្រាប់សិស្ស

- គ្រឿងបរិក្ខារ និងធនធាននានាដើម្បីគាំទ្រការរៀនសូត្រ។

***កម្រងព័ត៌មានអំពីការរួមបញ្ចូលពិការភាព***

កម្រងព័ត៌មានអំពីការរួមបញ្ចូលពិការភាពនឹងជួយដល់សាលារៀននានាឱ្យស្វែងយល់បន្ថែមទៀតអំពីចំណុចខ្លាំង និងសេចក្តីត្រូវការរបស់កូនអ្នក។ វានឹងជូនព័ត៌មានអំពីការបែងចែកមូលនិធិជាលក្ខណៈបុគ្គល ជួយរៀបចំផែនការសម្រាប់ការសិក្សារបស់សិស្ស និងការផ្លាស់ប្តូរណាមួយដែលសិស្សអាចត្រូវការដើម្បីរៀនសូត្រឱ្យកាន់តែប្រសើរ។




ដំណើរការនៃកម្រងព័ត៌មានអំពីការរួមបញ្ចូលពិការភាពថ្មីនឹងដាក់ជំនួសកម្រងសំណួរអំពីសេចក្តីត្រូវការផ្នែកអប់រំ ដែលត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃ PSD បច្ចុប្បន្ន។

នៅពេលដែលសាលារៀនធ្វើអន្តរកាលទៅកាន់វិធីសាស្ត្រថ្មី ក្រុមគ្រួសារនៃសិស្សទាំងឡាយដែលជាផ្នែកនៃ PSD នឹងត្រូវបានស្នើសុំឱ្យចូលរួមប្រជុំមួយ ដើម្បីបំពេញកម្រងព័ត៌មានអំពីការរួមបញ្ចូលពិការភាព។

មនុស្សដែលស្គាល់កូនរបស់អ្នកនឹងចូលរួមនៅក្នុងការប្រជុំនេះ ជាមួយអ្នកសម្របសម្រួលដែលបានបណ្តុះបណ្តាលឯករាជ្យដែលនឹងជួយសាលារៀន និងគ្រួសារនានាឱ្យបំពេញកម្រងព័ត៌មាននេះ។

ប្រសិនបើកូនរបស់អ្នកជាផ្នែកនៃ PSD សាលារៀនរបស់អ្នកនឹងធ្វើការជាមួយអ្នកដើម្បីស្វែងរកពេលវេលាដែលសមស្របបំផុតដើម្បីបំពេញកម្រងព័ត៌មានរបស់ពួកគេ។

កម្រងព័ត៌មាននេះក៏នឹងមានសម្រាប់ក្រុមសិស្សទូលំទូលាយនានាដែលមានសេចក្តីត្រូវការខ្ពស់។

***មូលនិធិអន្តរកាល***

ដើម្បីជួយដល់ក្រុមគ្រួសារនូវភាពប្រាកដប្រជាថែមទៀតនៅពេលដែលកូនរបស់ពួកគេធ្វើអន្តរកាលពីកម្មវិធីសម្រាប់សិស្សដែលមានពិការភាព (PSD) ទៅកាន់វិធីសាស្ត្រថ្មី រដ្ឋាភិបាលរដ្ឋវិចថូរៀកំពុងផ្តល់មូលនិធិអន្តរកាលការរួមបញ្ចូលពិការភាពរហូតដល់ឆ្នាំ 2024។

មូលនិធិអន្តរកាលការរួមបញ្ចូលពិការភាព ធ្វើឱ្យប្រាកដថាសាលារៀននានាទទួលបានចំនួននៃមូលនិធិកម្រិតសិស្សដូចគ្នា ឬច្រើនជាង ដើម្បីគាំទ្រដល់អន្តរកាលរបស់សិស្សពី PSD ទៅការរួមបញ្ចូលពិការភាព។

សម្រាប់ព័ត៌មានបន្ថែម និងរបៀបដែលមូលនិធិអន្តរកាលការរួមបញ្ចូលពិការភាពអនុវត្តចំពោះកាលៈទេសៈរបស់កូនអ្នក សូមទាក់ទងនាយកសាលារបស់អ្នក។

*ការបណ្តុះបណ្តាល និងការបង្វឹកបន្ថែមសម្រាប់គ្រូបង្រៀន និងបុគ្គលិកសាលា*

ការរួមបញ្ចូលពិការភាពនឹងផ្តល់ដល់គ្រូបង្រៀន និងបុគ្គលិកសាលាកាន់តែច្រើននូវការយល់ដឹងអំពីពិការភាព និងរបៀបឆ្លើយតប។ នេះអាចរួមមានការចូលប្រើប្រាស់៖

- អ្នកជំនាញនៅក្នុងសាលារៀនបានកាន់តែច្រើន ដែលជាអ្នកជំនាញខាងពិការភាព
- ការបង្វឹក
- ការរៀនសូត្រវិជ្ជាជីវៈ
- ការណែនាំផ្នែកលើកស្ទួតាង និងធនធាន
- អាហារូបករណ៍។

*ព័ត៌មានបន្ថែម*

ចូលមើល www.education.vic.gov.au/disabilityinclusion ដើម្បីស្វែងយល់បន្ថែមអំពីការរួមបញ្ចូលពិការភាព។

ប្រសិនបើអ្នកចង់និយាយអំពីសេចក្តីត្រូវការរបស់កូនអ្នកនៅសាលារៀន ឬប្រសិនបើអ្នកត្រូវការជំនួយផ្នែកបកប្រែភាសាសរសេរ ឬបកប្រែផ្ទាល់មាត់ សូមទាក់ទងនាយកសាលារបស់អ្នក។